# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

Sabrina

## កិច្ចព្រមព្រៀងបន្ថែម

ស្តីពី

ការកំណត់ប្រាក់ឈ្នួល សំរាប់កម្មករនិយោជិតផ្នែកបោះពុម្ពក្នុងកំឡុងពេលព្យួរការងារជាបណ្ដោះអាសន្ន

យោង: -សេចក្តីណែនាំ លេខ ០៤៥/២០ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថាន ក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩

-អនុសញ្ញារួម រវាងក្រុមហ៊ុន និងតំណាងសហជីព ស៊ីខៅឌូ ប្រចាំក្រុមហ៊ុនចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩

-សំណើររបស់សហជីព ( ស៊ីខៅឌូ) ដែលមានភាពតំណាងបំផុត ប្រចាំក្រុមហ៊ុន

ដោយការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កនូវផលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការផលិតកម្មរបស់ក្រុមហ៊ុន និងការធ្លាក់ចុះនូវការបញ្ជាទិញរបស់អ្នកបញ្ជាទិញ បានធ្វើអោយក្រុមហ៊ុន (សាប្រ៊ីណា ខេមបូឌា) មានការខាតបង់ និងពុំមានលទ្ធភាពក្នុងការផ្តល់ការងារជូនដល់បងប្អូនកម្មករនិយោជិត នៅតាមក្រុម ឬផ្នែកមួយចំនួន ។

ដើម្បីស្រោចស្រង់ស្ថានការណ៍ និងធ្វើយ៉ាងណាកុំឱ្យប៉ះពាល់ដល់ផ្នែក ឬក្រុមផ្សេងៗ ជាពិសេសប៉ះពាល់ដល់ក្រុមហ៊ុនទាំងមូល ហេតុដូច្នេះ ក្រុមហ៊ុន សាប្រ៊ីណា និងសហជីពស៊ីខៅឌូ ដែលមានភាពតំណាងបំផុតប្រចាំក្រុមហ៊ុន បានប្រជុំពិភាក្សាជាមួយកម្មករនិយោជិត ក្នុងផ្នែកដែលទទួលរងការប៉ះពាល់ តាមរយៈតំណាងរបស់ពួកគាត់ និង បានឯកភាពគ្នាដូចខាងក្រោម៖

ប្រការ១ : ភាគីទាំងពីរ បានព្រមព្រៀងគ្នាថានឹងធ្វើការព្យួរការងារជាបណ្តោះអាសន្ន សម្រាប់កម្មករនិយោជិតក្នុងផ្នែកបោះពុម្ពទាំងអស់ ។

ប្រការ២ : ការព្យួរការងារជាបណ្តោះអាសន្ន នេះ នឹងធ្វើឡើងលើកម្មករនិយោជិត ចំនួន ៧៣នាក់ សម្រាប់រយៈពេលចំនួន ១ខែ ពោលពី ថ្ងៃទី០១ ខែកក្កដា រហូតដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ។

ប្រការ៣ : ការព្យួរការងារជាបណ្តោះអាសន្ននេះ ភាគីក្រុមហ៊ុនបានឯកភាពធ្វើការបង់ប្រាក់ឈ្នួល ដោយបូកបង្គ្រប់ជាមួយនឹងប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាល (៤០ ដុល្លាអាមេរិច) ស្មើនឹង ឬមិនអោយលើសពីប្រាក់ឈ្នួល ចំនួនពាក់កណ្តាល (៥០%) នៃប្រាក់ឈ្នួលប្រចាំខែ របស់កម្មករនិយោជិតម្នាក់ៗ ។

ប្រការ៤ : ភាគីតំណាងសហជីព/តំណាងកម្មករនិយោជិត បានឯកភាព និងសូមធ្វើការបញ្ជាក់ថា ការបង់ប្រាក់ឈ្នួលដូចបានបញ្ជាក់ក្នុងប្រការ៣ ខាងលើ គឺសម្រាប់អនុវត្តន៍ តែក្នុងករណីពិសេសនេះ(លើកនេះ) តែប៉ុណ្ណោះ ។ ករណីមានការព្យួរកិច្ចសន្យាការងារផ្ទុយពីនេះ ឬមានរូបភាពប្រហាក់ប្រហែលនេះ ឬមានទ្រង់ទ្រាយធំជាងនេះ ឬផ្សេងពីនេះ ភាគីរោងចក្រ និងភាគីកម្មករនិយោជិតអនុវត្តតាមគោលការណ៍ ដែលមានចែងក្នុងច្បាប់ ឬលិខិតគតិ្តយុត្តិជាធរមាន ប៉ុណ្ណោះ។

ប្រការ៥ : កិច្ចព្រមព្រៀងទាំងឡាយណាផ្ទុយពីខ្លឹមសារនៃកិច្ចព្រមព្រៀងនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៦ : កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាព និងអនុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃព្រហស្បតិ៍៥កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅសាប្រីណា ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២០

| សហជីព ប្រជាធិបតេយ្យកម្មករកាត់ដេរ (សហជីព ស៊ីខៅខ្លូ) ប្រចាំ ក្រុមហ៊ុន សាប្រីណា | | | ក្រុមហ៊ុន សាប្រីណា |
|---|---|---|---|
| ប្រធាន | អនុប្រធាន | លេខាធិការ | នាយិកាក្រុមហ៊ុន |
| ឈា វិនុត | ឆន សុខឃៀន | ឃី សារ៉ាត | ឈិន ស៊ីងអ៊ឹង |